# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ
# ចំការទៀង ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៩
# ឲ្យយើងសម្លឹងមើលឈើឆ្កាងនិងព្រះផ្នូរព្រះយេស៊ូ

**អត្ថបទទី១៖ កិច្ចការ ១០,៣៤.៣៧-៤៣**

ពេលនោះ លោកសិលាចាប់ផ្ដើមមានប្រសាសន៍ថា៖ «ឥឡូវនេះ ខ្ញុំបានយល់យ៉ាងច្បាស់ហើយថា ព្រះជាម្ចាស់រាប់រកមនុស្សទូទៅឥតរើសមុខឡើយ។ កក ១០,៣៤

**អត្ថបទទី២៖ កូឡូស ៣,១-៤**

ចូរគិតពីអ្វីៗដែលនៅស្ថានលើ កុំគិតពីអ្វីនៅលើផែនដីនេះឡើយ។ កូឡ ៣,២

**ដំណឹងល្អ៖ យ៉ូហាន ២០,១-៩**

នាងក៏រត់មកជម្រាបលោកស៊ីម៉ូនសិលា និងសាវ័កម្នាក់ទៀត ដែលព្រះយេស៊ូស្រឡាញ់ថា៖ «គេយកព្រះអម្ចាស់ចេញពីផ្នូរបាត់ហើយ យើងមិនដឹងជាគេយកទៅដាក់នៅឯណាទេ!»។ យហ ២០,២

បងប្អូនជាទីស្រឡាញ់!

យប់នេះ ខ្ញុំមានអំណរសប្បាយក្នុងការចែករំលែក ធម្មទេសនានៅក្នុងភូមិភាគភ្នំពេញទាំងមូល។ យប់មិញនៅព្រែកប្បាស យើងបានធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់បងប្អូន១៨នាក់ នៅព្រះសហគមន៍គិរីវង់យើងមាន៥នាក់ និងនៅប៉ុន្មានកន្លែងក្នុងភូមិភាគភ្នំពេញយើងមានព្រះសហគមន៍នីមួយៗដែលបានធ្វើពិធីជ្រមុជទឹក។

យប់នេះ នៅព្រះសហគមន៍សន្ដីម៉ារីញញឹមចំការទៀង ខ្ញុំមានអំណរសប្បាយទទួលស្វាគមន៍បងប្អូន៥៥នាក់ ដែលមកពីព្រះសហគមន៍សន្ដីម៉ារីញញឹមនេះ មកពីព្រះសហគមន៍ថ្មីៗនៅត្រពាំងក្រញូង (ជាលើកទីមួយដែលមានពិធីជ្រមុជទឹក) មកពីព្រះសហគមន៍ទីរូមខេត្តតាកែវ និងមកពីព្រះសហគមន៍សន្តប៉ូល។ យប់នេះជាអំណរសប្បាយសម្រាប់ព្រះសហគមន៍នៅក្នុងខេត្តតាកែវ និងសម្រាប់ព្រះសហគមន៍នៅក្នុងភូមិភាគភ្នំពេញ ព្រះសហគមន៍នៅក្នុងប្រទេសកម្ពុជា ដែលព្រះជាម្ចាស់បានជ្រើសរើស៥៥នាក់ថែមទៀត ដើម្បីទៅជាបុត្រាបុត្រីរបស់ព្រះអង្គ និងជាពិសេសដើម្បីចូលរួមនៅក្នុងមហាគ្រួសាររបស់ព្រះជាម្ចាស់ ដែលជាព្រះសហគមន៍។ រួមជាមួយគ្នាពិតមែន យើងចង់ស្រែកយ៉ាងឮថា "**ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ អាលេលូយ៉ា អាលេលូយ៉ា!**"។

បងប្អូនជាទីស្រឡាញ់!

**នៅទីនេះយើងមានឈើឆ្កាង** ពីប៉ុន្មានថ្ងៃហើយដែលយើងគោរពព្រះយេស៊ូសោយទិវង្គត។ នៅពេលយើងនឹកឃើញព្រះយេស៊ូនៅលើឈើឆ្កាង នៅក្នុងដួងចិត្តរបស់យើង នៅក្នុងជីវិតរបស់យើងគឺយើងសោកស្ដាយ យើងឈឺចិត្តដែរ។ បងប្អូនមួយចំនួនដែលបានចូលរួមនៅក្នុងពិធីគោរពឈើឆ្កាង បានក្រាបថ្វាយបង្គំនៅមុខឈើឆ្កាងនេះ ដែលព្រះបុត្រារបស់ព្រះជាម្ចាស់បានសោយព្រះទិវង្គត ហើយនៅពេលនោះយើងបានបន្ទាបខ្លួនឱនកាយដើម្បីថើបព្រះបាទារបស់ព្រះយេស៊ូ ដែលបានបូជាជីវិតសម្រាប់យើង។ នៅពេលយើងនឹកឃើញព្រះយេស៊ូដែលជាព្រះអម្ចាស់ ព្រះដ៏វិសុទ្ធ សុចរិត យើងមិនយល់ទេថាមូលហេតុអ្វីព្រះយេស៊ូបានសោយព្រះទិវង្គត? មូលហេតុអ្វីបានជាព្រះជាម្ចាស់បានណែនាំឲ្យព្រះយេស៊ូ ដែលជាព្រះបុត្រាដ៏ជាទីស្រឡាញ់ឲ្យសោយព្រះទិវង្គតនៅលើឈើឆ្កាងនេះ?

ខ្ញុំដឹងថាបងប្អូនជិតមួយម៉ឺននាក់ បានមើលនៅពេលយើងកំពុងផ្សាយផ្ទាល់ ការសម្តែងអំពី ព្រះយេស៊ូសោយព្រះទិវង្គតនៅលើវេទិកាចំការទៀងនេះ។ មានបងប្អូនច្រើនបានឆ្ងល់ថាមូលហេតុអ្វីបានជាគ្រីស្តបរិស័ទ គោរពព្រះយេស៊ូដែលសោយព្រះទិវង្គតនៅលើឈើឆ្កាង? មូលហេតុអ្វីបានជាគ្រីស្តបរិស័ទក្រាបថ្វាយបង្គំ និងថើបឈើឆ្កាងដោយមានព្រះដ៏វិសុទ្ធដែលសោយព្រះទិវង្គត?

នៅពេលយើងនៅក្បែរឈើឆ្កាង នៅពេលនោះយើងនឹកឃើញៈ ទុក្ខលំបាកនៃជីវិតរបស់យើង យើងនឹកឃើញពីជីវិតរបស់យើងជួនកាលនៅក្នុងភាពងងឹត និងជីវភាពក្រីក្ររបស់យើង យើងនឹកឃើញដល់កូនក្មេង មានកូនក្មេងប៉ុន្មាននាក់នៅលើទឹកដីយើង ដែលអត់មានសមត្ថភាពទៅរៀនសូត្រ ដែលអត់មានសមត្ថភាពទៅមន្ទីរពេទ្យនៅពេលគេឈឺ។ យើងនឹកឃើញដល់ស្ត្រីមេម៉ាយ ដែលប្តីបោះបង់ចោលឬប្តីស្លាប់។ យើងនឹកឃើញដល់អ្នកដែលអត់មានម្ហូបគ្រប់គ្រាន់ ដើម្បីឲ្យកូនរបស់គេញ៉ាំឆ្អែត។ យើងនឹកឃើញដល់ពេលដែលយើងចាស់ជរា អត់មានអ្នកទីពឹងដើម្បីលើកទឹកចិត្តយើង។ កូនរបស់យើងទៅធ្វើការនៅប្រទេសគេអស់ហើយ យើងនៅទីនេះពីមួយថ្ងៃទៅមួយថ្ងៃយើងខិតខំរកម្ហូបអាហារតិចតួចដើម្បីចិញ្ចឹមជីវិត។

យើងអាចនឹកឃើញរឿងច្រើននៅក្នុងជីវិតរបស់យើង ដែលណែនាំឲ្យយើងពិបាក ជំងឺដែលយើងមាន ទុក្ខលំបាកដែលយើងមាន ការឈឺចាប់ដែលយើងមាន និងនៅពេលដែលយើងឃើញឈើឆ្កាងរបស់ព្រះគ្រីស្ត ហើយនៅពេលដែលយើងបានថ្វាយបង្គំនៅមុខឈើឆ្កាងនេះ។ ខ្ញុំនឹកឃើញថែមទៀត ដោយសារយើងមិនមែនមានមើលតែបងប្អូននៅទីនេះ នៅក្នុងខេត្តតាកែវ នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែយើងត្រូវការបើកភ្នែករបស់យើងមើលពិភពលោកយើងដែរ ព្រឹកមិញនៅប្រទេសស្រីលង្កា គេបានបំផ្ទុះគ្រាប់បែកនៅ៦កន្លែង ផ្ទុះនៅក្នុងព្រះវិហារកាតូលិករបស់

យើងពាកន្លែង ដែលមានគ្រីស្តបរិស័ទកំពុងអធិដ្ឋាន អរព្រះគុណព្រះជាម្ចាស់ដែលមានព្រះជន្មរស់ឡើងវិញ។ ផ្ទុះនៅក្នុងសណ្ឋាគារពាកន្លែងទៀត មានជាង១៥០នាក់ដែលបានបាត់បង់ជីវិតនេះដោយសារការស្អប់ ការមើលងាយសាសនា ដោយមិនព្រមទទួលស្គាល់មនុស្សមានសិទ្ធិសេរីភាពកាន់សាសនាតាមការជ្រើសរើសរបស់គេ ដោយសារយើងមិនចេះបង្កើតភេតរភាព និងមិនណែនាំឲ្យពិភពលោករបស់យើង ក្លាយជាក្រុមគ្រួសារមួយដែលចេះស្រឡាញ់គ្នាទៅវិញទៅមក។

នៅពេលយើងមើលឈើឆ្កាង យើងនឹកឃើញដល់ទីក្រុងប៉ារីស ដែលប៉ុន្មានថ្ងៃមុនវិសាលវិហារបានឆេះ យើងបានឃើញវិហាររបស់ព្រះជាម្ចាស់ដែលកំពុងត្រៀមខ្លួន ដើម្បីថ្វាយអភិបូជាសម្រាប់ព្រះពរលើប្រេងពិសិដ្ឋ នៅថ្ងៃព្រះយេស៊ូសោយទិវង្គត នៅថ្ងៃដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ព្រះវិហារនេះបានឆេះពេញមួយយប់។ អណ្តាតភ្លើងនេះ ណែនាំឲ្យយើងភ្ញាក់ស្មារតី និងសួរសំណួរនៅក្នុងដួងចិត្តរបស់យើងថា **តើយើងបានធ្វើអ្វីដល់ព្រះជាម្ចាស់? តើយើងចេះគោរពព្រះជាម្ចាស់ពិតមែនឬ? តើយើងស្រឡាញ់ព្រះជាម្ចាស់ពិតមែនទេ? តើយើងចេះយកព្រះជាម្ចាស់ជាអតិភាពនៅក្នុងជីវិតរបស់យើងឬទេ?** ពេលយើងឃើញវិសាលវិហារដែលមានអាយុជាង៨០០ឆ្នាំ ដែលបានឆ្លងបដិវត្តន៍ បានឆ្លងកាត់សង្គ្រាមច្រើនណាស់ ព្រះវិហារនេះបានឆេះដូចភ្លើងរបស់យើងអំបាញ់មិញ។ នេះណែនាំឲ្យយើងសួរ **ឱព្រះជាម្ចាស់អើយ តើខ្ញុំចេះស្រឡាញ់ព្រះអង្គឬទេ?**

*ប៉ុន្តែយប់នេះព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ អាលេលូយ៉ា អាលេលូយ៉ា!*

**យើងមើលព្រះភ័ក្ត្ររបស់ព្រះយេស៊ូ** យប់នេះជាយប់នៃសេចក្តីសង្ឃឹម យើងដឹងថាគ្រប់ភាពងងឹតដែលយើងបានផ្ញើទៅលើព្រះឈើឆ្កាងរបស់ព្រះយេស៊ូ យប់នេះភាពងងឹតនេះពោរពេញដោយសេចក្តីសង្ឃឹម ពោរពេញដោយពន្លឺថ្មី គឺពន្លឺនៃជីវិតដែលយើងបានឃើញអំបាញ់មិញផ្ទាល់ភ្នែក ពន្លឺដែលណែនាំឲ្យជីវិតរបស់យើងទៅជាជីវិតថ្មី ណែនាំឲ្យបងប្អូនដែលទទួលអគ្គសញ្ញាជ្រមុជទឹកយប់នេះ ដឹងថាបន្តិចទៀតគេកើតសារជាថ្មី ណែនាំឲ្យយើងអរព្រះគុណព្រះជាម្ចាស់ និងណែនាំឲ្យយើងភ្ញាក់ស្មារតី។ នៅពេលយើងឃើញជីវិតក្រីក្ររបស់យើង នៅពេលយើងឃើញទុក្ខលំបាករបស់យើង យើងដឹងថាយើងមិនមែនឯកោ យើងមិននៅម្នាក់ឯង គឺយើងមានព្រះយេស៊ូយប់នេះដែលប្រមូលគ្រប់ទុក្ខលំបាកយើង ដែលចាប់ដៃរបស់យើងដើម្បីធ្វើដំណើរជាមួយយើងតទៅទៀត។ ជាពិសេស ដើម្បីណែនាំឲ្យយើងដឹងច្បាស់ថា គ្រប់ភាពងងឹតមានផ្កាយដ៏តូចមួយដែលបំភ្លឺផ្លូវ ផ្កាយដែលបានណែនាំហោរាចារ្យទៅថ្វាយបង្គំព្រះយេស៊ូប្រសូត។ នៅក្នុងភាពងងឹតនៃជីវិតរបស់យើង មានអណ្តាតភ្លើងដ៏តូចមួយដែលណែនាំឲ្យ

យើងដឹងថា ខ្ញុំមានមិត្តភក្តិ ខ្ញុំមានគ្រីស្តបរិស័ទ ខ្ញុំមានព្រះយេស៊ូគ្រីស្តដែលជាទីពឹងរបស់ខ្ញុំ ដែលចាប់ដៃខ្ញុំជាកុមារកំព្រារ ជាស្ត្រីមេម៉ាយ ជាចាស់ជរា ជាអ្នកគ្មានទីពឹង ជាអ្នកក្រីក្រដែលដាច់ពេល យប់នេះយើងដឹងថាព្រះយេស៊ូចាប់ដៃរបស់យើង ដើម្បីឲ្យយើងធ្វើដំណើរតទៅទៀត ដើម្បីមានសេចក្តីស្រឡាញ់និងសេចក្តីសង្ឃឹមនៅក្នុងជីវិត ទោះបីគេមើលងាយយើង ទោះបីគេរិះគន់យើង ទោះបីគេនិយាយដើមយើង យើងដឹងថាដោយសារព្រះគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ ខ្ញុំមានសេចក្តីក្លាហានណាស់ ខ្ញុំមានភាពអង់អាចដើម្បីទៅមុខទៀត ព្រះអង្គធ្វើដំណើរជាមួយខ្ញុំ កែប្រែភាពងងឹតនៃជីវិតរបស់ខ្ញុំ ភាពងងឹតនៃពិភពលោក ដើម្បីទៅជាពន្លឺដ៏ត្រចះត្រចង់ ណែនាំឲ្យបំភ្លឺជីវិតរបស់យើងសារជាថ្មីដើម្បីទៅមុខ ពោរពេញដោយសេចក្តីសង្ឃឹមពិតមែន។ បងប្អូនជាទីស្រឡាញ់ **កុំខ្លាចអី! ព្រះយេស៊ូគង់នៅជាមួយយើង។**

នៅពេលខ្ញុំមើលព្រះភ័ក្ត្ររបស់ព្រះយេស៊ូ ដែលបំភ្លឺយប់នេះ ខ្ញុំនឹកឃើញដល់សង្គ្រាម ដល់ភាវរកម្ម ដល់របៀបដែលគេបំផ្លាញគ្រីស្តបរិស័ទ ដល់របៀបដែលគេសម្លាប់មនុស្សនៅប៉ុន្មានប្រទេស យើងជាប្រជារាស្ត្ររបស់ព្រះនៃសេចក្តីសង្ឃឹម យើងជាគ្រួសារមួយយ៉ាងពិសេសដែលមានសមត្ថភាព ដើម្បីបង្កើតភេតរភាពនៅក្នុងពិភពលោក។ ដូច្នេះ មនុស្សដែលចង់សម្លាប់អ្នកដទៃ មនុស្សដែលចង់ធ្វើបាបអ្នកដទៃមិនអាចឈ្នះទេ ដោយសារមានតែភេតរភាព មានន័យថាយើងជាបងប្អូនគ្នា យើងជាមនុស្សដែលចេះលើកទឹកចិត្តគ្នា យើងជាគ្រួសារមួយយ៉ាងធំដែលចេះស្រឡាញ់គ្នា។ សេចក្តីស្រឡាញ់របស់យើងរីកទៅៗនៅក្នុងប្រទេសកម្ពុជា នៅក្នុងពិភពលោករបស់យើង គឺពោរពេញដោយមនុស្សដែលមានចិត្តល្អ មានចិត្តសុចរិត អាចចាប់ដៃគ្នាដើម្បីធ្វើដំណើរជាមួយគ្នា នោះមនុស្សដែលមានគំនិតអាក្រក់ មនុស្សដែលមានចិត្តឃោរឃៅមិនអាចឈ្នះបានទេ មានតែសេចក្តីស្រឡាញ់ មានតែភេតរភាពដែលជោគជ័យ នេះជាអត្ថន័យនៃព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ។

នៅពេលខ្ញុំមើលព្រះភ័ក្ត្ររបស់ព្រះយេស៊ូ ខ្ញុំនឹកឃើញវិសាលវិហារនៅទីក្រុងប៉ារីសដែលបានឆេះ ប៉ុន្តែខ្ញុំនឹកឃើញដល់ព្រះជាម្ចាស់ ដែលមិនបានលះបង់ចោលប្រជារាស្ត្ររបស់ព្រះអង្គ។ ពីថ្ងៃដែលព្រះជាម្ចាស់បានបង្កើតមនុស្សជាបុរសជាស្ត្រី នៅពេលព្រះជាម្ចាស់បានចាប់ដៃប្រជារាស្ត្រហេប្រឺ ដើម្បីធ្វើដំណើរឆ្លងសមុទ្រក្រហមជាមួយលោកម៉ូសេ រហូតដល់ព្រះជាម្ចាស់ចាត់ព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ ដើម្បីធ្វើដំណើរជាមួយយើងសព្វថ្ងៃ ខ្ញុំដឹងថាព្រះជាម្ចាស់មិនលះបង់ចោលយើង។ ប៉ុន្តែព្រះជាម្ចាស់ណែនាំឲ្យយើងភ្ញាក់ស្មារតី កុំឲ្យយើងបោះបង់ទំនាក់ទំនងជាមួយព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង កុំឲ្យយើងបាត់បង់ជីវិតខាងផ្លូវវិញ្ញាណដែលណែនាំឲ្យយើងចេះមើលព្រះជាម្ចាស់ដែលនៅខាងលើ ដែលធ្វើដំណើរជាមួយយើង ដែល

ណែនាំឲ្យជីវិតរបស់យើងទៅជាជីវិតដែលចេះមើលទៅលើ ដើម្បីលើកឡើងអំពីតម្លៃថ្លៃថ្នូរនៃជីវិត ដើម្បីលើកឡើងអំពីតម្លៃនៃជីវិតរបស់យើងរៀងៗខ្លួន។ កុំឲ្យយើងគិតតែពីភាពអាត្មានិយម កុំឲ្យយើងគិតអំពីសុខមាភាពផ្ទាល់ខ្លួនតែប៉ុណ្ណឹង ប៉ុន្តែព្រះជាម្ចាស់ណែនាំឲ្យបេះដូងរបស់យើង ភ្នែករបស់យើង ដួងចិត្តរបស់យើងបើកចំហរយ៉ាងធំណាស់ ដើម្បីស្រឡាញ់ ដើម្បីមានជីវិតថ្មី ដោយសារយប់នេះយើងកើតជាថ្មីតាមផ្លូវវិញ្ញាណ នៅក្នុងទឹកនិងនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងកើតសារជាថ្មី ដោយសារចាប់ពីពេលនេះតទៅយើងជាប់ជាមួយព្រះជាម្ចាស់ និងព្រះជាម្ចាស់មិនដែលលះបង់ចោលយើងទេ។ ដូច្នេះអណ្តាតភ្លើងដែលយើងបានឃើញនៅលើដំបូលនៃវិសាលវិហារនៅទីក្រុងប៉ារីស ប្រហែលណែនាំឲ្យគ្រីស្តបរិស័ទនៅក្នុងពិភពលោកទាំងមូលភ្ញាក់ស្មារតីសារជាថ្មី និងគិតផ្ទាល់ខ្លួនជំនឿរបស់ខ្ញុំទៅដល់ណា សេចក្តីស្រឡាញ់របស់ខ្ញុំចំពោះព្រះជាម្ចាស់ទៅដល់ណា សេចក្តីស្រឡាញ់របស់ខ្ញុំចំពោះបងប្អូនឯទៀតៗទៅដល់ណា។ យប់នេះដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ជាយប់ដែលព្រះបិតាបង្ហាញសេចក្តីស្រឡាញ់របស់ព្រះអង្គ ដែលណែនាំឲ្យព្រះយេស៊ូចេញពីភាពងងឹតនៃសេចក្តីស្លាប់ ដើម្បីចូលនៅក្នុងពន្លឺនៃជីវិត យប់នេះជាឱកាសមួយដើម្បីប្រកាសជំនឿរបស់យើងសារជាថ្មី ដោយសារសន្យាថា ឱព្រះជាម្ចាស់អើយ! សូមអាណិតមេត្តាទូលបង្គំ និងណែនាំឲ្យទូលបង្គំនៅក្នុងឆ្នាំថ្មីខាងមុខឲ្យខ្ញុំចេះអធិដ្ឋាន ឲ្យខ្ញុំចេះស្តាប់ព្រះបន្ទូលរបស់ព្រះអង្គ ឲ្យខ្ញុំចេះថែរក្សាជីវិតខាងផ្លូវវិញ្ញាណរបស់ខ្ញុំ ដើម្បីទៅជាគ្រីស្តបរិស័ទដែលភ្ជាប់ជាមួយព្រះអង្គយ៉ាងពិតប្រាកដមែន។

បងប្អូនជាទីស្រឡាញ់!

យប់នេះ ជាយប់ដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ជាយប់ដែលណែនាំឲ្យយើងបង្កើតគ្រួសារមួយយ៉ាងពិសេស គ្រួសាររបស់គ្រីស្តបរិស័ទ។ ថ្ងៃនេះអរព្រះគុណព្រះជាម្ចាស់សម្រាប់បងប្អូន៥៥នាក់ដែលនឹងទទួលជីវិតថ្មីបន្តិចទៀត ដែលបានចូលនៅក្នុងមហាគ្រួសាររបស់យើង។ ខ្ញុំអរព្រះគុណព្រះជាម្ចាស់ សម្រាប់បងប្អូនដែលបានយកចិត្តទុកដាក់ពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីបង្កើតទំនាក់ទំនងជាមួយបងប្អូនឯទៀតៗនៅក្នុងសេចក្តីសុខ នៅក្នុងសុខដុមរមនា នៅក្នុងភាតរភាព ដោយសារពិតមែនយើងជាបងប្អូនបង្កើត ដែលមានព្រះបិតាតែមួយ។ ខ្ញុំអរព្រះគុណព្រះជាម្ចាស់ ដែលណែនាំឲ្យយប់នេះយើងភ្ញាក់ស្មារតីដើម្បីនឹកឃើញដល់ពិធីជ្រមុជទឹករបស់យើង នឹកឃើញដល់ជំនឿរបស់យើង ដើម្បីបន្តធ្វើដំណើរជាមួយព្រះយេស៊ូគ្រីស្តដែលមានព្រះជន្មរស់ឡើងវិញ។ ស្ត្រីៗបានធ្វើដំណើរដល់រូងថ្មពីព្រលឹមឡើង គេបានឃើញផ្នូរទទេ គេបានស្តាប់លឺព្រះបន្ទូលថាព្រះយេស៊ូលែងនៅទីនេះហើយ ព្រះអង្គទៅកាលីឡេមុនបងប្អូនហើយ។ ស្ត្រីៗហ្នឹង បានរត់ទៅប្រកាសដំណឹងល្អនេះដល់ក្រុមគ្រីស្តទូត។ បងប្អូនជាទីស្រឡាញ់

នៅក្នុងភូមិភាគភ្នំពេញទាំងមូល ឲ្យយើងភ្ញាក់ស្មារតីនៅក្នុងយប់ដ៏សុខសាន្តនេះដែលព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ដូចស្ត្រីៗឲ្យយើងស្ដាប់ ឲ្យយើងមើលឃើញ និងជាពិសេសឲ្យយើងទៅប្រកាសដំណឹងល្អព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញហើយ ព្រះអង្គណែនាំឲ្យពិភពលោករបស់យើងចេញពីភាពងងឹត ដើម្បីបង្កើតសេចក្ដីស្រឡាញ់នៅគ្រប់ទីកន្លែងដែលយើងរស់នៅជាគ្រីស្តបរិស័ទ ជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់។

**ព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ អាលេលូយ៉ា អាលេលូយ៉ាង!** អាម៉ែន៕